# ផែនការការគ្រប់គ្រងបរិស្ថាន សង្គម និងអាកាសធាតុសម្រាប់ អនុគម្រោងយុទ្ធសាស្ត្រ

## សេចក្តីសង្ខេប

ឯកសារនេះគឺជាផែនការនៃការគ្រប់គ្រងបរិស្ថាន សង្គម និងអាកាសធាតុ (ESCMP) សម្រាប់អនុគម្រោងយុទ្ធសាស្ត្រ ដែលជាផ្នែកមួយនៃគម្រោងប្រព័ន្ធធារាសាស្ត្រធន់នឹងអាកាសធាតុ និងកសិកម្មដែលមានភាពធន់ និងមាននិរន្តរភាព (កេសរ) នៅកម្ពុជា។ គម្រោងនេះមានគោលបំណងដើម្បីបង្កើនការធ្វើកសិកម្មបន្សាំនឹងអាកាសធាតុ ភាពធន់ ការប្រើប្រាស់ធនធានទឹកឱ្យមានប្រសិទ្ធភាព និងបង្កើនផលិតកម្មកសិកម្ម ព្រមទាំងជំរុញការអនុវត្តប្រកបដោយចីរភាព។ អនុគម្រោងយុទ្ធសាស្ត្រផ្តោតសំខាន់លើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងការលើកកម្ពស់ការអនុវត្តកសិកម្មនៅតំបន់ស្ទឹងក្រាំងពន្លៃ។

ផែនការគ្រប់គ្រងបរិស្ថាន សង្គម និងអាកាសធាតុ (ESCMP) បានដើរតួយ៉ាងសំខាន់ដើម្បីបញ្ជាក់ថាគម្រោងបានអនុវត្តដោយចីរភាពតាមរយៈការបង្ហាញអំពីផលជះសំខាន់ៗនៃបរិស្ថាន និងសង្គម។ វាបង្ហាញពីវិធានការនៃការកាត់បន្ថយហានិភ័យទាក់ទងនឹងការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងវិស័យកសិកម្ម។ ទិដ្ឋភាពសំខាន់មួយនៃ ESCMP គឺការផ្តោតសំខាន់លើការគ្រប់គ្រងធនធានទឹក ដោយសារស្ទឹងយុទ្ធសាស្ត្រមាន សារៈសំខាន់សម្រាប់វិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។ ផែនការនេះលើកកម្ពស់ការអនុវត្តប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនប្រសិទ្ធភាពការប្រើប្រាស់ទឹក និងកាត់បន្ថយហានិភ័យនៃការខ្វះខាតទឹក ជាពិសេសនៅក្នុងតំបន់ដែលងាយនឹងជួបគ្រោះរាំងស្ងួត។

ESCMP បានទទួលស្គាល់ពីសក្តានុពលនៃផលប៉ះពាល់សង្គមតាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ សកម្មភាពនេះសង្កត់ធ្ងន់ទៅលើការចូលរួមរបស់សហគមន៍ពេញមួយវដ្តជីវិតរបស់គម្រោង ដើម្បីដោះស្រាយកង្វល់ និងធានាថាជីវភាពក្នុងតំបន់ ជាពិសេសអ្នកដែលពឹងផ្អែកលើការធ្វើកសិកម្ម និងការនេសាទ មិនបានប៉ះពាល់អវិជ្ជមាននោះឡើយ។ ចំណុចទាំងនេះរួមបញ្ចូលដោយការពិគ្រោះយោបល់ ការផ្តល់សំណងសមរម្យសម្រាប់ការទទួលបានដីណាមួយ និងវិធានការដើម្បីកាត់បន្ថយការរំខានដល់រចនាសម្ព័ន្ធសង្គមដែលមានស្រាប់។ ផែនការនេះក៏គូសបញ្ជាក់ពីសារៈសំខាន់នៃការអនុលោមតាមស្តង់ដារបរិស្ថាន និងសង្គមថ្នាក់ជាតិ និងកម្រិតអន្តរជាតិ ដែលមានសារៈសំខាន់សម្រាប់ការធានាការផ្តល់មូលនិធិ និងការអនុលោមតាមការអនុវត្តល្អបំផុតជាសកលក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលបំណងរបស់ ESCMP រួមមាន៖

- ការកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម។
- ការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យ និងផលប៉ះពាល់។
- ការចូលរួមពីក្រុមដែលរងផលប៉ះពាល់ និងក្រុមងាយរងគ្រោះក្នុងដំណើរការវាយតម្លៃ និងកាត់បន្ថយ។

ESCMP សម្រាប់អនុគម្រោងយុទ្ធសាស្ត្រគ្របដណ្តប់សកម្មភាពគម្រោងក្រោមសមាសភាគទី១ (ការកែលម្អការបន្សាំអាកាសធាតុ ភាពធន់ និងប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក) និងសមាសភាគទី២ (ការកែលម្អលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក)។ ទីតាំងភូមិសាស្ត្ររបស់គម្រោងគឺស្ថិតនៅក្នុងអាងស្ទឹងក្រាំងពន្លៃ ដែលអនុគម្រោងយុទ្ធសាស្ត្រស្ថិតនៅផ្នែកខាងឆ្វេងនៃស្ទឹងក្រាំងពន្លៃ។ ក្នុងមួយទសវត្សរ៍ចុងក្រោយ តំបន់នេះប្រឈមមុខនឹងបញ្ហាធម្មជាតិដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់។ ការវិនិយោគដែលបានស្នើឡើងរួមមាន៖

- ការស្តារ និងការកែលម្អប្រព័ន្ធប្រឡាយដែលមានស្រាប់
- ការសាងសង់ប្រឡាយទឹកទី៣
- ការដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ
- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់សហគមន៍កសិករប្រើប្រាស់ទឹក (FWUCs)។
- សេវាផ្សព្វផ្សាយកសិកម្មសម្រាប់ការកែលម្អការអនុវត្តកសិកម្ម និងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ។

ពេលវេលានៃការអនុវត្តគម្រោងដោយមានការរចនាយ៉ាងលម្អិតនឹងចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៥ ហើយបន្តដោយដំណើរការលទ្ធកម្ម និងការសាងសង់។ ការសាងសង់រំពឹងថានឹងចាប់ផ្តើមនៅត្រីមាសចុងក្រោយនៃឆ្នាំ ២០២៦ ហើយនឹងបញ្ចប់រួចរាល់នៅពាក់កណ្តាលឆ្នាំ ២០២៣០។ ESCMP បានកំណត់ពីហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានក្នុងដំណាក់កាលផ្សេងៗនៃគម្រោង ព្រមទាំងបានស្នើពីវិធានការក្នុងការកាត់បន្ថយបញ្ហាទាំងនោះផងដែរ។

ហានិភ័យដែលអាចកើតមានមុន និងអំឡុងពេលសាងសង់មានដូចជា:

- គ្រាប់មីនមិនទាន់ផ្ទុះ (UXO)៖ វត្តមានរបស់ UXO ទាមទារឱ្យមានការបោសសម្អាត និងការវាយតម្លៃពីអ្នកជំនាញ មុនពេលចាប់ផ្តើមសកម្មភាពសាងសង់ណាមួយ។
- ការបំពុលខ្យល់ និងសំឡេង៖ វិធានការទប់ស្កាត់ធូលី កាត់បន្ថយម៉ោងប្រតិបត្តិការសម្រាប់គ្រឿងម៉ាស៊ីន និងការថែទាំជាប្រចាំត្រូវបានស្នើឡើងដើម្បីកាត់បន្ថយការបំពុលបរិយាកាស និងសំឡេងរំខាន។
- ការបំពុលទឹក៖ សំណង់គ្រប់គ្រង និងបញ្ចៀសទឹក ការរឹតបន្តឹងលើការចាក់ដីបំពេញប្រឡាយ និងការចោលកាកសំណល់ឱ្យបានត្រឹមត្រូវ គឺជាកត្តាសំខាន់ក្នុងការទប់ស្កាត់ការបំពុលទឹក។
- សំណល់រឹង និងគ្រោះថ្នាក់៖ ផែនការគ្រប់គ្រងកាកសំណល់ រួមទាំងការកំណត់កន្លែងចាក់សំរាមគឺត្រូវការជាចាំបាច់ ដើម្បីដោះស្រាយការទុកដាក់ប្រភេទសំរាមផ្សេងៗនៃសំណល់ដែលបានបង្កើតអំឡុងពេលសាងសង់។
- សំណល់ទឹក៖ ចាំបាច់ក្នុងការចាត់ចែង និងការចោលសំណល់ទឹកដែលមានគ្រោះថ្នាក់ ដូចជាប្រេង ឬឥន្ធនៈ។
- ផលប៉ះពាល់នៃជីវចម្រុះ៖ ចាំបាច់ត្រូវមានវិធានការនៃការកាត់បន្ថយការបាត់បង់ និងការបែកបាក់ទីជម្រក ទប់ស្កាត់ការរីករាលដាលនៃប្រភេទពូជរាតត្បាត និងលើកកម្ពស់ការយល់ដឹងអំពីការការពារសត្វព្រៃ។
- ផលប៉ះពាល់សង្គម៖ ផលប៉ះពាល់ទាំងនេះមានដូចជាលំហូរពលកម្ម សុខភាព និងសុវត្ថិភាពសហគមន៍ SEA/SH (ការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ) និងគ្រោះថ្នាក់ចរាចរណ៍។ វិធានការ

នៃការកាត់បន្ថយគឺពាក់ព័ន្ធជាមួយនឹងផែនការគ្រប់គ្រងការងារ យុទ្ធនាការបញ្ជ្រាបការយល់ដឹង ការបណ្តុះបណ្តាលអំពីសុវត្ថិភាព និងយន្តការដោះស្រាយបណ្តឹងតវ៉ាមិនសុខចិត្ត។

អំឡុងពេលប្រតិបត្តិការ ហានិភ័យមានដូចជា៖

- ការបំពុលទឹក៖ ESCMP ផ្តោតសំខាន់លើតម្រូវការសម្រាប់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព រួមទាំងការគ្រប់គ្រងសត្វល្អិតចម្រុះ (IPM) ដើម្បីកាត់បន្ថយហានិភ័យនៃការបំពុលទឹកពីសកម្មភាពកសិកម្ម។
- ផលប៉ះពាល់ជីវៈចម្រុះ៖ បន្តការត្រួតពិនិត្យ និងការគ្រប់គ្រងគឺចាំបាច់ដើម្បីដោះស្រាយបញ្ហានៃការបាត់បង់ និងបែកខ្ញែកទីជម្រកក្នុងរយៈពេលវែង។
- បម្រែបម្រួលអាកាសធាតុ៖ ការលើកកម្ពស់ប្រព័ន្ធធារាសាស្ត្រដែលមានប្រសិទ្ធភាពទៅលើថាមពល កាត់បន្ថយការពឹងផ្អែកលើឥន្ធនៈ និងការទទួលយកការអនុវត្តកសិកម្មឆ្លាតវៃតាមអាកាសធាតុ គឺជាគន្លឹះក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។

ESCMP បានបង្ហាញពីផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ព្រមទាំងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ ផែនការនេះធានាថា សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀតបានទទួលពត៌មានអំពីគម្រោងនេះ និងមានឱកាសដើម្បីបញ្ចេញនូវកង្វល់ និងសំណូមពររបស់ពួកគេ។ ESCMP ក៏បានដាក់បញ្ចូលនូវយន្តការដោះស្រាយបណ្តឹងតវ៉ាមិនសុខចិត្តដើម្បីដោះស្រាយជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់។ យន្តការនេះផ្តល់នូវដំណើរការដែលមានរចនាសម្ព័ន្ធសម្រាប់ការដោះស្រាយបញ្ហាទាក់ទងនឹងការទិញយកដីធ្លី កម្លាំងពលកម្ម SEA/SH និងកង្វល់ផ្សេងៗទៀតទាក់ទងនឹងគម្រោង។ ផែនការនេះក៏រៀបរាប់លម្អិតអំពីការរៀបចំការអនុវត្តដោយបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធផ្សេងៗដូចជាទីភ្នាក់ងាររដ្ឋាភិបាល អ្នកម៉ៅការ និងទីប្រឹក្សា ក្នុងការអនុវត្ត និងត្រួតពិនិត្យ ESCMP ។

ការចំណាយប៉ាន់ស្មានសម្រាប់ការអនុវត្ត ESCMP គឺ USD ១៥២,០០០ ដោយរួមបញ្ចូលទាំងការចំណាយសម្រាប់ការបោសសំអាត UXO ការវាយតម្លៃផលប៉ះពាល់ដីធ្លី ការគ្រប់គ្រងជីវចម្រុះ ការផ្សព្វផ្សាយសហគមន៍ និងសកម្មភាពត្រួតពិនិត្យ លើកលែងថវិកាសម្រាប់ការផ្លាស់ប្តូរទីលំនៅ ដែលនឹងត្រូវធ្វើការគណនានៅពេលក្រោយយោងទៅតាម ការប៉ានស្មានដែលនឹងធ្វើឡើងទៅតាមទស្សនទានបឋម នៃការរចនាប្លង់គម្រោងនាចុងខែធ្នូឆ្នាំ ២០២៤ខាងមុខនេះ។ កម្មវិធីត្រួតពិនិត្យ មានដូចជាការត្រួតពិនិត្យជាប្រចាំនូវគុណភាពដី ខ្យល់ និងទឹក បានប៉ាន់ប្រមាណថាមានតម្លៃ ១០,៥០០ ដុល្លារ។